State of California—Health and Human Services Agency
# ក្រសួងសុខាភិបាលសាធារណៈរដ្ឋកាលីហ្វូញ៉ា

**TOMÁS J. ARAGÓN, M.D., Dr.P.H.**
**នាយកនិង មន្ត្រីសុខាភិបាលសាធារណរដ្ឋ**

**GAVIN NEWSOM**
អភិបាល

12 កក្កដា 2023

**ជូនចំពោះ៖**
ជូនចំពោះនិយោជករដ្ឋកាលីហ្វ័រញ៉ាទាំងអស់

**ប្រធានបទ៖**
ការឆ្លើយតបចំពោះកូវីដ-19ក្នុងទីកន្លែងធ្វើការសម្រាប់និយោជក

**សម្ភារៈទាក់ទង ៖** ការណែនាំសម្រាប់និយោជិត និងកន្លែងធ្វើការ | ការណែនាំទាំងអស់ | ភាសាពិស្តារទៀត

**ធ្វើឲ្យមានបច្ចុប្បន្នភាពថ្ងៃទី 12 ខែកក្កដា ឆ្នាំ 2023៖**

- ធនធានថ្មីទាក់ទងនឹងបទប្បញ្ញត្តិការទប់ស្កាត់កូវីដ-19 មិនបន្ទាន់របស់ Cal/OSHA។
- សេចក្តីយោងមានបច្ចុប្បន្នភាពសម្រាប់របាយការណ៍និងការណែនាំ ការផ្ទុះរាលដាល។
- ការណែនាំ និងតំណទាក់ទងនឹងការពាក់ម៉ាសបានធ្វើបច្ចុប្បន្នភាព។

## ការឆ្លើយតបចំពោះកូវីដ-19ក្នុងទីកន្លែងធ្វើការ

និយោជកមានមុខតំណែងយ៉ាងសំខាន់ក្នុងការរក្សានិយោជិតឲ្យមានសុវត្ថិភាពពីកូវីដ-19។ ឯកសារធនធាននេះត្រូវបានបង្កើតឡើង ដើម្បីជួយនិយោជកឲ្យយល់អំពីជំហានដែលពួកគេអាចធ្វើ ដើម្បីការពារការរីករាលដាលនៃ កូវីដ-19 និងដើម្បីឆ្លើយតបឲ្យបានឆាប់រហ័ស និងសមស្របចំពោះករណី និងការផ្ទុះឡើងនៃ កូវីដ-19 ដែលត្រូវបានកំណត់នៅកន្លែងធ្វើការ ។

*ក្រសួងសុខភាពក្នុងមូលដ្ឋាន (LHD) អាចបន្តអនុវត្តតម្រូវការបន្ថែមដែលតឹងរ៉ឹងជាងការណែនាំទូទាំងរដ្ឋនេះ ដោយផ្អែកលើកាលៈទេសៈក្នុងតំបន់ រួមទាំងនៅក្នុងទីកន្លែងដែលមានហានិភ័យខ្ពស់ ឬក្នុងស្ថានភាពជាក់លាក់មួយចំនួន (ឧទាហរណ៍ អំឡុងពេលមានការផ្ទុះសកម្មនៅក្នុងទីកន្លែងដែលមានហានិភ័យខ្ពស់)។*

## តម្រូវការខាងច្បាប់និងបទប្បញ្ញត្តិ

តម្រូវការទូទាំងរដ្ឋពីមុនសម្រាប់និយោជកក្នុងការជូនដំណឹង LHD អំពីការផ្ទុះឡើងនៃកន្លែងការងារកូវីដ-19 លែងមានសុពលភាពទៀតហើយ។ ប៉ុន្តែ LHD អាច បន្តដើម្បីតម្រូវនូវរបាយការណ៍ការផ្ទុះឡើងតាមរយៈបទបញ្ជាក្នុងមូលដ្ឋាន។ និយោជកត្រូវតែផ្តល់ព័ត៌មានបានស្នើសុំដោយ LHDទាក់ទងនឹងករណីកូវីដ-19

ឬការផ្ទុះឡើងក្នុងទីកន្លែងធ្វើការ ដូចដែលបានពណ៌នានៅក្នុង ការណែនាំរបាយការណ៍ការផ្ទុះឡើងក្នុងកន្លែងធ្វើការចំពោះកូវីដ-19។

នៅកន្លែងធ្វើការដែលមិនមែនជាការថែទាំសុខភាព និយោជកមានទំនួលខុសត្រូវក្នុងការធានាថាសកម្មភាពរបស់ពួកគេដើម្បីការពារនិយោជិតត្រូវអនុវត្តតាម បទប្បញ្ញត្តិ Cal/OSHA ការបង្ការ កូវីដ-19 មិនមែនគ្រាអាសន្ន (បទប្បញ្ញត្តិការបង្ការកូវីដ-19)។

និយោជកត្រូវតែប្រឹក្សាជាមួយភាសា សំណួរស៊ើបសួរជាញឹកញាប់, និងឯកសារសម្ភារៈអំពីគេហទំព័របទប្បញ្ញត្តិស្តីពីការបង្ការជំងឺកូវីដ-19។
មគ្គុទ្ទេសក៍ធនធាននេះមិនមានបំណងដើម្បីរំលឹកឡើងវិញនូវ តម្រូវការដ៏ទូលំទូលាយនៃបទប្បញ្ញត្តិ Cal/OSHA នោះទេ។

ការណែនាំអំពីធនធាននេះក៏មិនត្រូវបានបម្រុងទុក សម្រាប់ប្រើប្រាស់ក្នុងការគ្រប់គ្រង ឬការពារការផ្ទុះឡើងនៅក្នុងការថែទាំសុខភាព ការកែតម្រូវ ទីជម្រក ឬការកំណត់កន្លែងធ្វើការផ្សេងទៀតដែលស្តង់ដារ ជម្ងឺអាចចម្លងពីចំហាយដំណ៍ (Aerosol Transmissible Diseases, ATD) របស់ Cal/OSHA) (ចំណងជើង 8 វគ្គ 5199) អនុវត្ត។

## *សមាសធាតុសំខាន់ៗនៃការគ្រប់គ្រងការផ្ទុះនៅកន្លែងធ្វើការ*

### 1. រៀបចំដើម្បីកំណត់និងគ្រប់គ្រងករណីកូវីដ-19 ក្នុងទីកន្លែងធ្វើការ។

- កំណត់ ព័ត៌មានទំនាក់ទំនង LHD និងតម្រូវការរាយការណ៍ ដែលអាចអនុវត្ត បានសម្រាប់ LHD នៅក្នុងដែនសមត្ថកិច្ចដែលកន្លែងធ្វើការស្ថិតនៅ។ នៅក្នុង យុត្តាធិការដែលកន្លែងធ្វើការស្ថិតនៅ។
- ចាត់តាំងអ្នកសម្របសម្រួលការគ្រប់គ្រង និងបង្ការជំងឺនៅកន្លែងធ្វើការ ដើម្បីជួយអនុវត្តនីតិវិធីបង្ការការឆ្លងកូវីដ-19 និងដើម្បីគ្រប់គ្រងបញ្ហាដែលទាក់ទងនឹងកូវីដ-19 ក្នុងចំណោមបុគ្គលិក។
- បង្កើតកម្មវិធីការពាររបួស និងជំងឺនៅកន្លែងធ្វើការ (IIPP) សម្រាប់នីតិវិធីការពារកូវីដ-19 ដែលស្របតាមតម្រូវការនៃ Cal/OSHA បទប្បញ្ញត្តិការពារជំងឺកូវីដ-19។ Cal/OSHA មានគំរូម៉ូដែលទម្រង់ការការការពារ កូវីដ-19 មានជូននៅ គេហទំព័របទបញ្ញត្តិមានបន្ទាន់ការពារកូវីដ-19។
- ប្រាប់និយោជិតឲ្យរាយការណ៍អំពីភាពគ្រោះថ្នាក់កន្លែងធ្វើការបណ្តាល មកពីកូវីដ-19 ដែលអាចកើតមានឡើងទៅនិយោជក ដោយគ្មានការភ័យខ្លាចចំពោះការសងសឹក។
- លើកទឹកចិត្តនិយោជិតឲ្យសម្រាកនៅផ្ទះហើយរាយការណ៍ទៅនិយោជក ប្រសិនបើពួកគេត្រូវបានវិនិច្ឆ័យរោគរកឃើញថាមានកូវីដ-19។
    - បញ្ជាក់ថានិយោជិតដឹងអំពី សំណងកម្មករ ការធានារ៉ាប់រងពិការភាពរបស់រដ្ឋ, ឬមានអត្ថប្រយោជន៍ការឈប់សម្រាក ដែលពួកគេអាចសមត្ថភាពដើម្បីនឹងទទួល។
- លើកទឹកចិត្តនិយោជិតទាំងអស់ឲ្យ ទទួលបានការចាក់វ៉ាក់សាំងកូវីដ-19 របស់ខ្លួនឲ្យទៀងទាត់ពេលវេលា។ ការចាក់វ៉ាក់សាំងគឺជាវិធានការមានប្រសិទ្ធិភាពបំផុតតែមួយ សម្រាប់ការការពារនិយោជិតពីកូវីដ-19។

### 2. ចែករំលែកព័ត៌មានជាមួយ LHD និងអ្នកពាក់ព័ន្ធផ្សេងទៀត។

- LHD គឺជាយុត្តាធិការស្ថិតនៅកន្លែងធ្វើការ **អាច** មានតម្រូវការរាយការណ៍ការផ្ទុះឡើងជាក់លាក់នានា។ និយោជក **ត្រូវតែ** អនុវត្តតាមតម្រូវការទាំងនេះ ហើយផ្តល់នូវព័ត៌មានស្នើសុំណាមួយដោយ LHD។ ក្នុងអវត្តមាននៃតម្រូវការរាយការណ៍ការផ្ទុះជាក់លាក់នានា និយោជកត្រូវបានលើកទឹកចិត្តឲ្យទាក់ទង LHD សម្រាប់ការណែនាំលើករណី និងការផ្ទុះឡើងតាមតម្រូវការ។
- ប្រសិនបើគ្រឹះស្ថានប្រើប្រាស់កិច្ចសន្យា ឬនិយោជិតបណ្តោះអាសន្ន សូមចាត់តាំងបុគ្គលម្នាក់ឱ្យទំនាក់ទំនងព័ត៌មាន និងការណែនាំអំពីការផ្ទុះឡើងដល់និយោជិត និងនិយោជករបស់ពួកគេ។

- ប្រឹក្សា Cal/OSHA's កត់ទុកនិងរាយការណ៍អំពីតម្រូវការសម្រាប់ករណីកូវីដ-19។

3. **កំណត់ករណីបុគ្គលិកបន្ថែម និងទំនាក់ទំនងជិតស្និទ្ធ។**

- នៅពេលដែលនិយោជិតម្នាក់ត្រូវបានគេកំណត់អត្តសញ្ញាណថាមាន កូវីដ-19 និយោជកគួរតែកំណត់ថា តើនិយោជិតនោះមានវត្តមាននៅកន្លែងធ្វើការឬអត់ក្នុងអំឡុងពេលឆ្លងរបស់ពួកគេ និងកំណត់ទំនាក់ទំនងជិតស្និទ្ធណាមួយ។ និយោជកគួរតែប្រឹក្សា បទបញ្ញត្តិការពារកូវីដ-19 របស់ Cal/OSHA ហើយ បទបញ្ជារបស់មន្ត្រីសុខាភិបាលសាធារណៈរបស់រដ្ឋ ការគ្រប់គ្រងនិងបង្ការជំងឺកូវីដ-19 សម្រាប់និយមន័យនៃរយៈពេលនៃការឆ្លង និងការទំនាក់ទំនងជិតស្និទ្ធ។
  - ដើម្បីវាយតម្លៃនៅពេលដែលបុគ្គលវិជ្ជមានកូវីដ-19 មានវត្តមាននៅកន្លែងធ្វើការ និងជួយកំណត់អត្តសញ្ញាណទំនាក់ទំនងជិតស្និទ្ធបន្ថែម និយោជកអាចជ្រើសរើសសម្ភាសន៍និយោជិតជាមួយកូវីដ-19 តាមទូរស័ព្ទ។ កំណត់ត្រាការងារក៏អាចត្រូវបានប្រឹក្សាដើម្បីទទួលបានព័ត៌មាននេះ។
  - ទំនាក់ទំនងជិតស្និទ្ធគួរតែធ្វើតាមការណែនាំរបស់នាយកដ្ឋានសុខភាពសាធារណៈរដ្ឋកាលីហ្វ័រញ៉ា (CDPH) សម្រាប់ការដាក់ឱ្យនៅដាច់ដោយឡែក និងការដាក់ឱ្យនៅដាច់ពីគេ ដែលរួមមានការណែនាំដូចខាងក្រោម៖ ពាក់ម៉ាស់ដែលសមរម្យសម្រាប់រយៈពេល 10 ថ្ងៃបន្ទាប់ពីការប៉ះពាល់។ ធ្វើតេស្តក្នុងរយៈពេល 3-5 ថ្ងៃបន្ទាប់ពីការប៉ះពាល់ចុងក្រោយ; នៅផ្ទះ ហើយ ធ្វើតេស្តម្តងទៀតប្រសិនបើរោគសញ្ញាកើតឡើង។
- កាលណា ការផ្ទុះឡើងនៅកន្លែងធ្វើការ ត្រូវបានកំណត់ ការធ្វើតេស្តនិយោជិតដែលអាចប្រឈមមុខនឹងហានិភ័យ គួរតែជាយុទ្ធសាស្ត្រដំបូងមួយដែលត្រូវបានពិចារណាដោយនិយោជក ដើម្បី កំណត់ករណីបន្ថែម។
  - LHD អាចត្រូវបានពិគ្រោះដើម្បីពិភាក្សាអំពីយុទ្ធសាស្ត្រសាកល្បង ហើយក៏អាចអាចជួយសម្រួលដល់ជម្រើសនៃការធ្វើតេស្ត ប្រសិនបើចាំបាច់។
  - ប្រឹក្សាបទបញ្ញត្តិការពារ កូវីដ-19 Cរបស់al/OSHA ស្តីពីតម្រូវការធ្វើតេស្តសម្រាប់និយោជិតត្រូវបានប៉ះពាល់ និងលក្ខណៈវិនិច្ឆ័យត្រឡប់ទៅធ្វើការវិញជាក់លាក់។
  - ត្រូវដឹងថា ការធ្វើតេស្តឆ្លុះបញ្ចាំងពីស្ថានភាពសុខភាពរបស់បុគ្គលម្នាក់ៗ នៅចំណុចតែមួយក្នុងពេលតែប៉ុណ្ណោះ។ ថ្វីបើនិយោជិតតេស្តឃើញថាអវិជ្ជមានក្តី ពួកគេនៅតែអាចបង្កើតការចម្លងកូវីដ-19 ពីទំនទាក់ទំនងថ្មីឬតាមក្រោមទៀត។ ធ្វើតេស្តម្តងទៀតប្រសិនបើរោគសញ្ញាកើតឡើងត្រូវបានណែនាំ តាមការណែនាំសម្រាប់ការនៅដាច់ដោយឡែក និងចត្តាឡីស័ករបស់ CDPH។

4. **ជូនដំណឹងនិងផ្តល់សេចក្តីណែនាំដល់និយោជិត។**

- ប្រសិនបើបុគ្គលដែលមានកូវីដ-19 នៅកន្លែងធ្វើការត្រូវបានគេកំណត់ឃើញ និយោជកត្រូវតែតាំងប្រកាសការជូនដំណឹងនៃការប៉ះពាល់កូវីដ-19 ក្នុងកន្លែងធ្វើការ។ សូមមើល ក្រមកូដពលកម្ម 6409.6 និង បទបញ្ញត្តិការពារកូវីដ-19របស់Cal/OSHA សម្រាប់ព័ត៌មានបន្ថែមអំពីតម្រូវការការជូនដំណឹង។

5. **សម្រេចនៅពេលណាដែលសហហេតុផលសម្រាប់និយោជិតដែលកើតមានកូវីដ-19 នឹងត្រឡប់មកធ្វើការវិញ។**

- និយោជកគួរតែពិនិត្យមើល តម្រូវការ Cal/OSHA និង CDPH ការណែនាំសម្រាប់ការដាក់ឱ្យនៅដាច់ដោយឡែក និងនៅដាច់ដោយឡៃ ដើម្បីកំណត់ថាតើនៅពេលណាដែលនិយោជិតដែលធ្វើតេស្តវិជ្ជមានសម្រាប់កូវីដ-19 អាចចូលធ្វើការវិញបាន។

- អំឡុងពេលហាមឃាត់មិនធ្វើការ អាចផ្លាស់ប្តូរផ្អែកទៅលើរោគសញ្ញានិង លទ្ធផលតេស្តរបស់បុគ្គលនោះ។
- LHD អាចដាក់លក្ខខណ្ឌតម្រូវឱ្យត្រឡប់ទៅធ្វើការបន្ថែម។ និយោជកគួរតែពិគ្រោះជាមួយ LHD នៅក្នុងយុត្តាធិការដែលកន្លែងធ្វើការស្ថិតនៅទាក់ទងនឹងតម្រូវការទាំងនេះ។

## 6. បញ្ចូលសកម្មភាពដើម្បីការពារនូវការរាលដាលកូវីដ-19 តទៅមុខទៀតក្នុងកន្លែងធ្វើការ។

- សូមពិគ្រោះជាមួយ CDPH ទទួលបានអត្ថប្រយោជន៍ច្រើនបំផុតពីម៉ាស ដើម្បីយល់ពីរបៀបវាយតម្លៃគុណភាពនៃរបាំងមុខ និងភាពខុសគ្នារវាងរបាំងមុខ និងឧបករណ៍ដកដង្ហើម។
    - និយោជកផ្តល់ម៉ាសជាមួយការសមនឹងមុខនិងតម្រងល្អ។
    - នៅក្នុងស្ថានភាពដែលមានហានិភ័យខ្ពស់ ដូចជាកន្លែងធ្វើការដែលមានដង់ស៊ីតេខ្ពស់ ឬការផ្ទុះនៅកន្លែងធ្វើការ ឬនៅពេលដែលមនុស្សជាច្រើននៅក្នុងសហគមន៍បច្ចុប្បន្ន អាចមានកូវីដ-19 និងឆ្លងទៅអ្នកដទៃ និយោជកគួរតែ **យ៉ាងខ្លាំង** ពិចារណាផ្តល់ឧបករណ៍ដកដង្ហើម N95 ដែលត្រូវបានអនុម័តដោយ NIOSH ដល់បុគ្គលិក។
- សូមពិគ្រោះជាមួយ Cal/OSHA បទប្បញ្ញត្តិការពារជំងឺកូវីដ-19 ដើម្បីស្វែងយល់ថាតើពេលណាត្រូវមានរបាំង ឬឧបករណ៍ដកដង្ហើមសម្រាប់និយោជិត និងវិធានការការពារបន្ថែមអ្វីខ្លះ ដែលត្រូវអនុវត្ត។
- សូមមើល បទប្បញ្ញត្តិការពារកូវីដ-19 របស់ Cal/OSHA និង CDPH ការណែនាំបណ្តោះអាសន្នសម្រាប់ខ្យល់ តម្រង និងគុណភាពខ្យល់នៅក្នុងបរិយាកាសក្នុងផ្ទះ សម្រាប់ ព័ត៌មានបន្ថែមអំពីរបៀបកែលម្អខ្យល់អាកាសនៅកន្លែងធ្វើការ។

### *ធនធាន CDPH បន្ថែម*

- សាខាសុខភាពការងារកូវីដ-19 និងកន្លែងធ្វើការ
- តម្រូវការរាយការណ៍ការផ្ទុះនៅកន្លែងធ្វើការ AB 685 កូវីដ-19 សម្រាប់នាយកដ្ឋានសុខភាពសាធារណៈក្នុងតំបន់
- ការណែនាំបណ្តោះអាសន្នសម្រាប់ខ្យល់ តម្រង និងគុណភាពខ្យល់នៅក្នុងបរិយាកាសក្នុងអគារ
    - កូវីដ-19 និងគន្លឹះគុណភាពខ្យល់ក្នុងអគារ
- ចំណុចសំខាន់និងធនធានសម្រាប់ម៉ាសមុខ
- សេចក្តីណែនាំសម្រាប់យុត្តាធិការសុខភាពមូលដ្ឋាន ស្តីពីការដាក់ឱ្យនៅដាច់ដោយឡែក និងចត្តាឡីស័ក
    - ការណែនាំចំពោះសំណួរនិងចម្លើយការនៅដាច់ដោយឡែកនិងចត្តាឡីស័ក

### *ធនធាន Cal/OSHA បន្ថែម*

- គេហទំព័រកូវីដ-19 របស់Cal/OSHA
    - សំណួរនិងចម្លើយជាញឹកញាប់បទប្បញ្ញត្តិមិនបន្ទាន់ ធនធាន និងសំណួរគេសួរញឹកញាប់អំពីការការពារ កូវីដ-19
    - កត់ទុកនិងរាយការណ៍អំពីតម្រូវការសម្រាប់ករណីកូវីដ-19។

បានចេញផ្សាយដំបូងក្នុងថ្ងៃទី 16 ខែមិថុនា ឆ្នាំ 2020